**ខ្លឹមសារសង្ខេបដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន សហចៅក្រមស៊ើបអង្កេត អវតក C22 ១៤ វិច្ឆិកា ២០០៧**

**ពាក្យគន្លឹះ÷** ការលើកលែងទោស ការឃុំខ្លួនបណ្ដោះអាសន្ន ការធានាឲ្យនៅក្រៅឃុំ ការហាមកាត់សេចក្ដីពីរដងក្នុងរឿងដូចគ្នា

## ១. អង្គហេតុ និងប្រវត្តិនីតិវិធី

អៀង សារី (IENG Sary: IS) ជាជនត្រូវចោទម្នាក់នៅមុខអវតក ត្រូវបានឃាត់ខ្លួន។ សហព្រះរាជអាជ្ញា បានស្នើឲ្យសហចៅក្រមស៊ើបអង្កេតឃុំខ្លួន IS ជាបណ្ដោះអាសន្ន ដោយលើកមូលដ្ឋានជាច្រើន ដូចជា ដើម្បីបង្ការការរត់គេច ឬទង្វើណាមួយសងសឹកដោយជនរងគ្រោះ ឬបង្ការការដាក់សំពាធលើសាក្សី។ IS ថ្លែងថា គាត់ទទួលបានការលើកលែងទោស គាត់បានរស់នៅជាយូរមកហើយដោយគ្មានហិង្សាលើគាត់ មិនមានការជ្រៀតជ្រែកនីតិវិធី ហើយគាត់នឹងមិនគេចទេ ប្រសិនបើគេច គាត់គេចខ្លួនយូរទៅហើយ។ បន្ថែមពីលើនេះ គាត់មានជំងឺ ដែលអាចស្លាប់ក្នុងមន្ទីរឃុំឃាំង។

## ២. សំអាងហេតុនិងសេចក្ដីសម្រេច

សហចៅក្រមស៊ើបអង្កេត (Co-Investigating Judges: CoIJ ) ពិនិត្យមើលទាំងអង្គហេតុដោះនិងដាក់បន្ទុក ដោយជាដំបូងបានពិនិត្យមើលបញ្ហាផ្លូវច្បាប់ចំនួនពីរ÷ ការហាមកាត់សេចក្ដីពីរដង និងការលើកលែងទោស ហើយបានរកឃើញថា វាមិនរារាំងដល់យុត្តាធិការអវតកទេ។ CoIJ បានបន្តពិនិត្យមើលមូលដ្ឋានសម្រាប់ឃុំខ្លួន។

ជាបឋម CoIJ ត្រូវរកឲ្យឃើញថាមានមូលដ្ឋានរឹងមាំ (well-founded reasons to believe) ជឿថា IS បានប្រព្រឹត្តបទឧក្រិដ្ឋចោទដោយសហព្រះរាជអាជ្ញាសិន។ CoIJ បានពិចារណា អ្វីដែលសហព្រះរាជអាជ្ញាបានស្នើឡើង ដោយផ្ដើមសង្កត់ធ្ងន់ថា កាលៈទេសៈឥឡូវវាខុសពីមុន ប្រសិនបើមានការដោះលែង (មិនឃុំខ្លួន) សុវត្ថិភាពរបស់ IS នឹងមានបញ្ហា។ ពាក់ព័ន្ធនឹងការដាក់សំពាធលើសាក្សី វាក៏នឹងកើតមាន ដោយសារគាត់ទទួលបានឯកសារ ដឹងឈ្មោះសាក្សី ***អវតក*** ពិបាកក្នុងការគ្រប់គ្រងនូវទំនាក់ទំនង បន្ថែមពីលើនេះ កូនចៅរបស់គាត់ កំពុងកាន់តំណែង ដែលជាជួយក្នុងរឿងដាក់សំពាធ។

សម្រាប់ការរត់គេច IS ធ្លាប់ធ្វើដំណើរក្រៅប្រទេស គាត់មានលិខិតឆ្លងដែន គាត់ធ្លាប់ធ្វើសេចក្ដីថ្លែងការណ៍ថានឹងមិនបង្ហាញខ្លួននៅមុខអវតក។ កម្ពុជា មិនមានសន្ធិសញ្ញាបត្យាប័នជាមួយប្រទេសជាច្រើនទេ ក្នុងករណីរត់គេច អវតក នឹងពិបាកក្នុងការស្នើសុំឲ្យបញ្ជូនជនត្រូវចោទមកកម្ពុជាវិញ។

ជាចុងក្រោយ ការដាក់ប្រាក់ធានាឲ្យនៅក្រៅឃុំ (bailing) ក៏មិនជាជម្រើសដែរ សម្រាប់ធានានូវហានិភ័យដែលបានលើកឡើងខាងលើ។

ដូចនេះការឃុំគឺជាការចាំបាច់ និងសមាមាត្រទៅនឹងអ្វីដែល ***អវតក*** ចង់បាន គឺរក្សា IS ទុកដើម្បីចូលរួមក្នុងនីតិវិធីនាពេលខាងមុខ។

## ៣. ខ្លឹមសារដកស្រង់ឬយោបល់

**ក.** រឿងបញ្ហាឃុំខ្លួន វាពាក់ព័ន្ធនឹងយុត្តាធិការ។ ក្នុងន័យថា ប្រសិនបើមិនមានយុត្តាធិការក្នុងការកាត់សេចក្ដីទេ មិនត្រូវឃុំជនត្រូវចោទទេ។ ដូចនេះក្នុងរឿងនេះ CoIJ ត្រូវពិចារណាមើលបញ្ហាចំនួន ២÷ គឺការហាមកាត់សេចក្ដីពីរដង (double jeopardy) និងការលើកលែងទោស (amnesty) ដែលជាបញ្ហាយុត្តាធិការ (jurisdictional issue) អាចរារាំង អវតក មិនឲ្យចោទប្រកាន់ឬកាត់ទោសបាន។

**ខ.** នីតិវិធីឃុំខ្លួនជានីតិវិធីតទល់ (adversarial hearing) អនុញ្ញាតឲ្យជនសង្ស័យ និងរដ្ឋអាជ្ញាតទល់គ្នាដើម្បីឲ្យចៅក្រមសម្រេច។ ដើម្បីអាចឃុំខ្លួនបាន ទាល់តែមានមូលដ្ឋាន នាំឲ្យការឃុំខ្លួនចាំបាច់ព្រមទាំងមានភាពសមាមាត្រ។ ការទាមទារដូចនេះ ដើម្បីកុំឲ្យប៉ះសិទ្ធិបុគ្គល ហើយក៏អាចបន្ថយភាពចង្អៀតណែនក្នុងពន្ធនាគារផងដែរ។

## ៤. ប្រភពនៃឯកសារ

សម្រាប់អត្ថបទទាំងស្រុងសូមចូលមើលគេហទំព័រ÷6e81c10344cc684694333d7e6e19f7ee.pdf